មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសជាមួយឈ្មោះ យក់ ហម ភេទប្រុស អាយុ៥៨ឆ្នាំ កើតឆ្នាំ១៩៥៣**

**មុខងារជំនាន់ខ្មែរក្រហមៈ “យោធាកងពល៨០១”**

**សព្វថ្ងៃនៅភូមិស្រះឈូក ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ផាត កុសល**

**០០:៥៧:៣៤**

**២៦ទំព័រ**

កុសលៈ លោកពូឈ្មោះ ពេញ ឈ្មោះអីទៅលោកពូ?

ហមៈ ខ្ញុំឈ្មោះ យក់ ហម ។

កុសលៈ ពូមានឈ្មោះ ហៅក្រៅដែរ?

ហមៈ បាទ!អត់ទេ ។

កុសលៈ ថ្ងៃខែឆ្នាំកំណើតពូ?

ហមៈ ០៥-០៨ ឆ្នាំ១៩៥៣ ។

កុសលៈ ទីកន្លែងកំណើតលោកពូ?

ហមៈ ទីកន្លែងកំណើតនៅភូមិសំព័រ ។

កុសលៈ ឃុំ?

ហមៈ ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ។

កុសលៈ ខេត្ត?

ហមៈ កំពង់ស្ពឺ ។

កុសលៈ ចឹងអាស័យដ្ឋានបច្ចុប្បន្នភូមិស្រះឈូក?

ហមៈ បាទ ។

កុសលៈ ឃុំ?

ហមៈ ឃុំត្រពាំងប្រិយ ។

កុសលៈ ខ្ញុំចាប់អារម្មណ៍ប្រវត្តិរបស់លោកពូតាំងពីមុនមក ទាក់ទងនិងគ្រួសារដើម្បីមុនហ្នឹងខ្ញុំសួរចូលនេះលោកពូ ជាពិសេសលោកពូជួយរំលឹកមុនឆ្នាំ៧៣ដល់ឆ្នាំ៧៥ លោកពូ?

ហមៈ បាទ ។

កុសលៈ តើសភាពការណ៍ពេលហ្នឹង សភាពការណ៍ស្រុកទេសយ៉ាងណាដែរ សភាពការណ៍គ្រួសាររបសពូយ៉ាងណាដែលពេលហ្នឹង សូមរៀបរាប់ឲ្យបានក្បោះក្បាយពូនៅចាំបានទេ?

ហមៈ វានៅចាំបានខ្លះដែរ ។

កុសលៈ បាទ ។

ហមៈ ចង់និយាយថា ៧៣ហ្នឹងគ្រួសារអ៊ីហ្នឹងជាគ្រួសារកសិករសុទ្ធសាធ ឪពុកម្ដាយជាកសិករសុទ្ធសាធធ្វើស្រែចម្ការហើយ ពេលនោះខ្ញុំជាកូនសិស្សនៅរៀនអនុវិទ្យាល័យសម្ដេចឪប្រទាននៅថ្នល់រការនៅរៀន មិញប៉ុន្មាន៧៣?

កុសលៈ បាទ! ៧៣ លោកពូដល់៧៣ហើយ ។

ហមៈ អូ! ៧៣ កាលនោះឈប់រៀនហើយ កសិករសុទ្ធសាធធ្វើស្រែធ្វើចម្ការ ។

កុសលៈ ចឹងសុំកាត់ប្រសាសន៍លោក៧០ ខែមិថុនា តែ៣ឆ្នាំ៧០ ហ្នឹង ពេលគេធ្វើរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ ហ្នឹង តើលោកពូនៅចាំបានទេព្រឹត្តិការណ៍ក្នុងថ្ងៃហ្នឹង?

ហមៈ កាលហ្នឹងខ្ញុំអត់នេះដែរ កាលហ្នឹងខ្ញុំនៅរៀនខ្ញុំនៅក្មេងដែលណាស់ ។

កុសលៈ បាទ ។

ហមៈ នៅរៀនឃើញគេដុតរូបសម្ដេចអីចឹងកាលនោះណាស់ ខ្ញុំសួរថាគេធ្វើអី គេថាទម្លាក់សម្ដេច សីហនុ ចឹងណាស់ ហើយយើងក៏មិនមានប្រត្តិកម្មអីដែរ តាមដំណើរចឹងទៅកាលហ្នឹងយើងនៅក្មេងៗដែរ ។

កុសលៈ ចឹងក្រោយមកទៀត?

ហមៈ យើងក្រោយមកខាងហ្នឹងរដប្រហារថ្ងៃ១៨ណាស់ ។

កុសលៈ បាទ!ថ្ងៃ១៨ មិថុនា ។

ហមៈ ដល់ក្រោយមកទៀតខ្ញុំនៅជាប្រជាជនធម្មតា ឈប់រៀនទៅកាលនោះណាស់ ឈប់រៀននៅធ្វើស្រែចម្ការជាមួយឪពុកម្ដាយ ។

កុសលៈ បាទ!ហើយឪពុកម្ដាយបងប្អូនរបស់ពូមានគ្នាប៉ុន្មាននាក់ដែរ?

ហមៈ ខ្ញុំបងប្អូនមាន៧នាក់ ។

កុសលៈ ឪពុកម្ដាយនៅរស់ទាំងអស់?

ហមៈ ឪពុកស្លាប់ហើយនៅម្ដាយចាស់ ។

កុសលៈ កាន់សាសនាព្រះពុទ្ធសាសនា?

ហមៈ បាទ!កាន់សាសនាព្រះពុទ្ធ ។

កុសលៈ ចឹងពូរៀបការហើយនៅមុនឆ្នាំ៧៥?

ហមៈ ខ្ញុំមិនទាន់រៀបការផង ។

កុសលៈ អាយុប៉ុន្មានហើយលោកពូ?

ហមៈ កាលហ្នឹងមិនដឹងជាអាយុប៉ុន្មានទេ ឥឡូវអាយុ៥៨ហើយ ។

កុសលៈ កាលហ្នឹងមិនទាន់មានកូនប្រពន្ធដែលនៅពេលហ្នឹង?

ហមៈ បាទ ។

កុសលៈ នៅកំពង់ស្ពឺនៅឡើយទេ កាលមុនឆ្នាំ៧៥?

ហមៈ បាទ!នៅជាមួយម៉ែឪ ។

កុសលៈ ចឹងសូមពូរៀបរាប់បន្តទៀតពេលថ្ងៃដែលប្រទេសជាតិច្របូកច្របល់ ពិសេសនៅអំឡុងឆ្នាំ៧២-៧៣ពូមាននៅចាំបានព្រឹត្តិការណ៍អ្វីខ្លះ ព្រឹត្តិការពេលហ្នឹង?

ហមៈ ឆ្នាំ៧៣ បើតាមខ្ញុំចាំកាលហ្នឹង តែអត់បានចាំថ្ងៃខែទេ ។

កុសលៈ បាទ ។

ហមៈ កាលនោះយើងវ៉ៃគ្នាខ្លាំងហើយសំខាន់យើងមានយន្តហោះ យន្តហោះ«បេ៥២»ណាស់ ។

កុសលៈ បាទ ។

ហមៈ ទម្លាក់កាលឆ្នាំ៧៣ហ្នឹង ។

កុសលៈ ជុំវិញកំពង់ស្ពឺតំបន់ហ្នឹង?

ហមៈ ជុំវិញកំពង់ស្ពឺ តំបន់ភ្នំអីហ្នឹង ។

កុសលៈ បាទ ។

ហមៈ ទម្លាក់ទាំងអស់ហើយក៏ចូលត្រង់សេអីចឹងទៅណាស់ ។

កុសលៈ គ្មានប៉ះពាល់ទ្រព្យសម្បត្តិនិងគ្រួសាររបស់ពូទេ?

ហមៈ ពិសេសផ្ទះខ្ញុំតែម្តង ផ្ទះខ្ញុំទម្លាក់ត្រូវដែរ តែកាលហ្នឹងយន្តហោះខាងភ្នំពេញ ។

កុសលៈ បាទ ។

ហមៈ ទម្លាក់ត្រូវខ្ទិចផ្ទះងាប់គោ កាលហ្នឹងខ្ញុំនៅភូមិតាប្រាជ្ញ ។

កុសលៈ កាលហ្នឹង?

ហមៈ បាទ!ភូមិតាប្រាជ្ញ ឃុំបសេដ្ឋហ្នឹង ។

កុសលៈ ដល់ក្រោយមកទៀតលោកពូ?

ហមៈ ក្រោយមក ។

កុសលៈ ពេលហ្នឹងលោកពូចូលបដិវត្តឆ្នាំណា?

ហមៈ ឆ្នាំ៧៣ហ្នឹងតែម្ដង ។

កុសលៈ បាទ!ដោយសារថាមូលហេតុអីបានជាលោកពូសម្រេចចិត្តចូលបដិវត្ត ដោយសារថា មកពីទម្លាក់ សម្ដេច សីហនុ ឬក៏ដោយសារថា មានទម្លាក់គ្រាប់បែករបស់អាមេរិច?

ហមៈ កាលនោះ កាលពិតទៅអ្នកដែលចូលទៅហ្នឹងត្រូវតែបំរើជាតិតែម្ដង គេឲ្យទៅតស៊ូ ។

កុសលៈ បាទ!ក្នុងភូមិនេះគេទៅទាំងអស់តែម្ដងឬមួយយ៉ាងម៉េច?

ហមៈ នៅក្នុងភូមិនេះទៅច្រើន ទាំងគេទាំងខ្ញុំខ្លះមានវាសនាល្អទៅ អ្នកខ្លះក៏បានរស់អ្នកខ្លះក៏ស្លាប់ទៅ ស្លាប់អស់ហើយ ។

កុសលៈ ខ្ញុំសង្កេតឃើញពេលហ្នឹងដោយសារថា មានការទម្លាក់គ្រាប់បែកវាប៉ះពាល់ដល់ភូមិឃុំ?

ហមៈ ហ្នឹងហើយ ។

កុសលៈ ជាពិសេសនៅកំពង់ស្ពឺបើតាមខ្ញុំដឹងមកមានទម្លាក់គ្រាប់បែកច្រើនមែនជំនាន់ហ្នឹង ជាពិសេសជំនាន់ឆ្នាំ៧៣?

ហមៈ បាទ ។

កុសលៈ មុនរបប លន់ នល់ ដួលរលំទៅ ចឹងលោកពូយល់ថា មូលហេតុហ្នឹងបានជាលោកពូចូលបដិវត្តជំនាន់ហ្នឹង ចូលទាហានហ្នឹងចង់ផ្តួលរំលំរបប លន់ នល់ ប្រឆាំងនិងអាមេរិចឬក៏យ៉ាងណាឬក៏ដោយសារសម្ដេចឪអំពាវនាវ?

ហមៈ តាមពិតទៅឆ្នាំ៧០ក៏មានការអំពាវនាវរបស់សម្ដេចដែរ ខ្ញុំបានឮតាមចាស់ៗគាត់ដឹកនាំមុនៗហ្នឹង ។

កុសលៈ បាទ ។

ហមៈ មេភូមិអីហ្នឹង ។

កុសលៈ បាទ ។

ហមៈ អំពាវនាវអ្នកក្រោយឲ្យចូលតស៊ូដើម្បីពន្លត់ប្រទេសជាតិមានការវិវត្តចឹងយើងក៏ចូលទៅកាលនោះខ្ញុំនៅក្មេងៗដែលហ្នឹងមិនទាន់ចាស់ ។

កុសលៈ បាទ!ឆ្នាំ៧៣នៅក្មេងដែរ?

ហមៈ បាទ!កាលហ្នឹង១៨ទៅ១៩ ។

កុសលៈ ចឹងកាលឆ្នាំ៧៣ដល់៧៥ហ្នឹងអត់មានបានរៀនទេឡូចប់ ៧៣ហ្នឹងពូឈប់តែម្ដង?

ហមៈ ឈប់ហើយ ។

កុសលៈ ដល់ថ្នាក់ទីប៉ុន្មានកាលឆ្នាំ៧៣ហ្នឹង?

ហមៈ ឈប់តាំងពី៧១-៧២នោះ ឈប់យូរហើយ ។

កុសលៈ រៀនដល់ថ្នាក់ទីប៉ុន្មានពេលហ្នឹងអនុវិទ្យាល័យ?

ហមៈ អនុវិទ្យាល័យ ។

កុសលៈ ថ្នាក់ទី៦-៧?

ហមៈ ថ្នាក់ទី៥ ។

កុសលៈ ថ្នាក់ទី៥ ចឹងលោកពូចូលបដិវត្តពេលហ្នឹង គឺដោយសារលោកពូចង់ទី១ដើម្បីប្រទេសជាតិ ប្រឆាំងនិងពួក លន់ នល់ និងពួកចក្រព័ត្តិអាមេរិចមិនចឹង?

ហមៈ បាទ!អាហ្នឹងចឹងឯង ។

កុសលៈ ចឹងលោកពូគិតថា បដិវត្តជំនាន់នោះអាចនាំនូវយុត្តិធម៌និងភាពស្មើគ្នាក្នុងសង្គមពូដែលគតទេ កាលហ្នឹង?

ហមៈ បាទ!កាលហ្នឹងខ្ញុំគិតដល់ហើយ កាលហ្នឹងគិតថា បើយើងបានសន្តិភាពទៅឈ្នះទៅ ក្រោយចប់សង្រ្គាមយើងបានយុត្តិធម៌ យើងបានកាលនោះគេថាប្រជាជនឲ្យស្មើមុខស្មើមាត់គ្នាយ៉ាងម៉េចទេណាស់ គេថាចឹងឯង ។

កុសលៈ ចឹងកាលហ្នឹងសភាពការណ៍ក្នុងភូមិចូលគ្រប់គ្នាកាលហ្នឹង?

ហមៈ កាលហ្នឹងមានភាគច្រើនណាស់ ។

កុសលៈ គេចុះមកអំពាវនាវប្រាប់ឬមួយយ៉ាងម៉េច?

ហមៈ កាលហ្នឹងសំខាន់អាជ្ញាធរមេភូមិតែម្តង អាជ្ញាធរភូមិឃុំហ្នឹងតែម្តង ។

កុសលៈ បាទ ។

ហមៈ គេប្រជុំចឹងគេណែនាំទៅណាស់ គេថាតស៊ូដើម្បីរំដោះប្រទេសជាតិ ក្រោយមកយើងមានមុខមាត់ស្មើភាពគ្នាចឹងទៅណាស់ ។

កុសលៈ បាទ ។

ហមៈ ហើយក៏នាំគ្នាចូលទៅតស៊ូ ។

កុសលៈ ចឹងក្រោយមកទៀតពូ ដល់ពេលប្រទេសរំដោះនៅថ្ងៃទី១៧មេសា ឆ្នាំ៧៥?

ហមៈ ក្រោយប្រទេសរំដោះខ្ញុំ ។

កុសលៈ ពូមាននៅចាំថ្ងៃហ្នឹងបានទេ ថ្ងៃរំដោះ?

ហមៈ ថ្ងៃរំដោះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ។

កុសលៈ ពេលហ្នឹងពូនៅណា នៅជួរមុខនៅវិជួរមុខឬមួយយ៉ាងម៉េច ពូមានធ្លាប់គេឲ្យទៅវៃនៅវៀតណាមទេកាលហ្នឹង?

ហមៈ អត់ដែលចូលទេ ។

កុសលៈ ចឹងថ្ងៃហ្នឹងពូនៅណាដែរ ពូចាំបានទេ?

ហមៈ ថ្ងៃ១៧មេសា ខ្ញុំនៅម្តុំខាងត្បូងភ្នំពេញ ។

កុសលៈ ផ្លូវជើងឯកតាមមើល?

ហមៈ អត់ទេ ។

កុសលៈ ផ្លូវទៅតាខ្មៅ?

ហមៈ នៅម្តុំទួលគី ។

កុសលៈ ចឹងថ្ងៃរំដោះហ្នឹងពូចូលមកជាមួយគេដែលពេលហ្នឹង?

ហមៈ បាទ ។

កុសលៈ ចូលមករំដោះភ្នំពេញ ទិដ្ឋភាពយ៉ាងម៉េចខ្លះទៅនៅតាមផ្លូវវាំងថ្ងៃហ្នឹង?

ហមៈ ខ្ញុំមិនបានចូលដល់ក្នុងទេ ខ្ញុំនៅក្រៅ ។

កុសលៈ ពូទៀមខ្សែក្រវ៉ាត់ក្រុង ពូឃើញទិដ្ឋភាពយ៉ាងម៉េចដែលនៅពេលហ្នឹង?

ហមៈ ទិដ្ឋភាពក្នុងថ្ងៃហ្នឹង គេចេញមកច្រើនតែម្តង គ្រាន់តែចូលទៅប្រជាជនចេញបណ្តោយ ចេញមកកកកុញគ្នា ខ្លះរុញឡាន ខ្លះម៉ូតូ អាខ្លះដើរចឹងទៅណាស់ ចេញមកក្រៅទាំងអស់ហ្នឹង យើងមិនដឹងថាគេទៅណាទេ ។

កុសលៈ តាមច្រកស្ពានទៅផ្លូវជាតិលេខមួយហ្នឹង?

ហមៈ អត់ទេ មកខាងត្បូងវិញ ។

កុសលៈ ត្បូងខាងណាចេះ?

ហមៈ ទៅម្តុំផ្លូវជាតិលេខ៣ ។

កុសលៈ អូ!ផ្លូវកំពត?

ហមៈ បាទ!ផ្លូវមកតាកែវ កំពតហ្នឹង ។

កុសលៈ ចឹងគេឲ្យពូធ្វើអីដែលយាមទីក្រុងឬមួយយ៉ាងមេចពេលហ្នឹង?

ហមៈ យើងនៅបានតែមួយរយៈយើងចេញមកវិញហើយ គេអត់ឲ្យចូលក្នុងភ្នំពេញទេ ។

កុសលៈ ក្នុងក្រុមរបស់លោកពូមានគ្នាច្រើនទេ នៅការពារខ្សែក្រវ៉ាត់ក្រុងហ្នឹង?

ហមៈ កាលហ្នឹងយើងមានកងវរៈរបស់យើងកាលហ្នឹង ។

កុសលៈ នៅក្រោមការកាន់កាប់របស់អ្នកណាគេ?

ហមៈ កាលហ្នឹងនៅកងពលទី២ ភូមិភាគនិរតី ។

កុសលៈ បាទ!នៅក្រោម តា ម៉ុក ជំនាន់ហ្នឹង ភូមិភាគនិរតី តា ម៉ុក គាត់ជាអ្នកកាន់ខាងហ្នឹង?

ហមៈ បាទ!ហើយក្រោយមកទៀតខ្ញុំទៅនៅព្រំដែន នៅម្តុំកោះអណ្តែតណាស់ ។

កុសលៈ ព្រំដែនវៀតណាម?

ហមៈ បាទ!កោះអណ្តែតយើងតាកែវ នៅកាហាងអីហ្នឹង ។

កុសលៈ នៅកាហាងហ្នឹងនៅក្នុងភូមិភាគនិរតីហ្នឹងដែរ?

ហមៈ បាទ!ដល់ឆ្នាំ៧៧ ខ្ញុំមកនៅរោងចក្រអាឈើ ។

កុសលៈ នៅរោងចក្រអាឈើនៅណា?

ហមៈ នៅរោងចក្រអាឈើនៅតាអង្គ ។

កុសលៈ នៅតាកែវហ្នឹងដែរ?

ហមៈ បាទ!នៅតាអង្គហ្នឹងនៅខាងលិចព្រែក្អួចនៅហ្នឹង សុទ្ធតែព្រៃ ។

កុសលៈ បាទ ។

ហមៈ ដល់ចេញមកទៀតមកបានមកនៅ ឆ្នាំ៧៧-៧៨ហ្នឹងមកនៅបាត់ដំបង ។

កុសលៈ គេបញ្ជូនមកបាត់ដំបង?

ហមៈ បាទ!នៅបាត់ដំបងនៅរោងចក្រអាឈើដែរ ។

កុសលៈ ចឹងខ្ញុំចង់សួរពូកាលឆ្នាំ៧៧-៧៨ហ្នឹងនៅភូមិភាគនិរតីហ្នឹង កាលហ្នឹងមានការប៉ះទង្គិចជាមួយវៀតណាមដែរ ព្រោះកាលហ្នឹងប្រទេសយើងមានជម្លោះជាមួយប្រទេសវៀតណាមខ្លាំង ជាពិសេសនៅភូមិភាគបូព៌ា?

ហមៈ បាទ ។

កុសលៈ ភូមិភាគនិរតីហ្នឹងពេលហ្នឹងចូលរួមសកម្មក្នុងការពារប្រទេសជាតិប្រឈមមុខវៃជាមួយពួកយួនពេលហ្នឹង ពូមានចាំបានទេ?

ហមៈ អត់ទេ កាលហ្នឹងខាងខ្ញុំអត់មានប៉ះពាល់ជាមួយវៀតណាមផង យើងគ្រាន់តែយាមម្ខាងម្នាក់ចឹងទៅគេ លួចឡើងគេមកតាមព្រំដែនគេ យើងនៅតាមព្រំដែនយើង ។

កុសលៈ ចឹងអត់មានដែលប៉ះទង្គិចគ្នាទេ ជាមួយពួកវៀតណាម?

ហមៈ អត់ទេ រហូតខ្ញុំមកដល់រោងចក្រអាឈើ ។

កុសលៈ លោកពូចេញមកឆ្នាំ៧៧ហ្នឹងក្នុងខែណា?

ហមៈ ឆ្នាំ៧៧ ខ្ញុំខែវស្សាដែរ មិនដឹងជាខែប៉ុន្មាន ។

កុសលៈ ឆ្នាំ៧៧ហ្នឹងមានការប៉ះទង្គិចខ្លាំងតាមខ្ញុំសិក្សាមកណាស់?

ហមៈ ប៉ុន្តែខាងខ្ញុំអត់នៅម្ដុំកាហាងហ្នឹង ។

កុសលៈ ចឹងមានទាហាននៅក្នុងកងពលហ្នឹង?

ហមៈ ទាហានមានដូចគ្នា ការពារដូចគ្នាតែមិនដែលបានវ៉ៃគ្នាទេ ប្រហែលជាខ្ញុំចេញមកហើយបានវ៉ៃ?

កុសលៈ នៅតំបន់កោះអណ្តែតហ្នឹង?

ហមៈ បាទ!អត់កោះអណ្តែតទេ មុំកាហាងហ្នឹង តែហ្នឹងហើយកោះអណ្តែតនៅក្រោយ ។

កុសលៈ បាទ ។

ហមៈ យើងនៅមុខ ។

កុសលៈ ចឹងឃើញទាហានវៀតណាមច្រើននៅខាងខ្សែព្រំដែន?

ហមៈ អត់មានឃើញទាហានផង ឃើញតែប្រជាជនគេថ្ងៃឡើងចឹងគេចាក់មេក្រូមេអឺច្រៀង ។

កុសលៈ បាទ!កាលហ្នឹងមានឆ្លងនិយាយគ្នាទៅវិញទៅមកទេ កាលហ្នឹង?

ហមៈ អត់!មាននិយាយគ្នាទេ ហើយខ្សែព្រំដែនវាតូចហ្នឹងមានអូរប្រហែលជាបួនម៉ែត្រ ។

កុសលៈ បាទ ។

ហមៈ គេនៅខាងគេចឹងទៅល្ងាចឡើងគេមកដាក់អង្គុបកណ្តុរអីចឹងទៅណាស់ យើងនៅតាមកាឡូសកូសពីដើម ។

កុសលៈ ចឹងការពារពូគេឲ្យការពារក្រវ៉ាត់ព្រំដែនឬមួយយ៉ាងម៉េចពេលហ្នឹង?

ហមៈ គេឲ្យធ្វើស្រែប្រាំង ។

កុសលៈ ចឹងកាលហ្នឹងទាហានក៏ធ្វើស្រែដែលកាលហ្នឹង?

ហមៈ បាទ!ធ្វើស្រែផងយើងយាមអីផងណាស់ ។

កុសលៈ បាទ! កាលហ្នឹងអត់មានប៉ះទង្គិចទេពេលហ្នឹង?

ហមៈ បាទ ។

កុសលៈ ចឹងក្នុងមួយកងវរៈហ្នឹងមានគ្នាប៉ុន្មាននាក់ដែលកាលហ្នឹង?

ហមៈ ប្រហែលជាច្រើនដែលកាលហ្នឹង គ្រប់ដែលកាលសម័យនោះ មួយអនុសេនាតូចវាមានបីក្រុមហើយមួយក្រុម១២នាក់ ចឹងមាន៣៦នាក់ ។

កុសលៈ ខ្ញុំឆ្ងល់កន្លែងហ្នឹងដែរ កាលហ្នឹងមានប៉ះទង្គិចជាមួយវៀតណាមហេតុអីក៏អត់មាន?

ហមៈ ប្រហែលជាខ្ញុំមកមុន ខ្ញុំមកមុនហើយបានគេវ៉ៃក្រោយ តាមខ្ញុំដឹង ។

កុសលៈ បាទ!ព្រោះកាលខែ១១ ឆ្នាំ១៩៧៧ហ្នឹងគឺមានការវាយលុកខ្លាំង កាលលោកពូចេញមកខែវស្សាចឹងមានមកមុនហ្នឹងបន្តិចចឹង?

ហមៈ បាទ!ខ្ញុំចេញមកមុន ។

កុសលៈ ចឹងកាលហ្នឹងហេតុអីបានគេបញ្ជូនមកខាងនេះ បញ្ជូនត្រឡប់មកបាត់ដំបងវិញ?

ហមៈ	គេឲ្យមកនៅរោងចក្រ រោងចក្រអារឈើ គេបញ្ជូនមកបាត់ដំបងហើយគេបញ្ជូនមក អះ! បញ្ជូនមកបុសតាផង់ហើយបានគេបញ្ជូនមកបាត់ដំបង ។

កុសលៈ	ពីណាជាអ្នកបញ្ជូនមកហ្នឹងកាលហ្នឹង ខាងណាជាអ្នកបញ្ជូនមក តា ម៉ុក ជាអ្នកបញ្ជូនមកឬមួយយ៉ាងម៉េច?

ហមៈ	កាលហ្នឹងចេះចង់និយាយថា គេសម្រាំងសមត្ថភាពថាយើងអ្នកមានអីមិនដឹង ដល់ចឹងគេបញ្ជូនចេញមកក្រោយ ។

កុសលៈ	ចឹងគ្រួសារលោកពូមកតាមជាមួយទេ គេឲ្យមកទាំងអស់ឬមួយយ៉ាងម៉េច?

ហមៈ	អត់ទេ កាលហ្នឹងមិនទាន់ការផង ។

កុសលៈ	ចឹងនៅម្នាក់ឯង?

ហមៈ	បាទ! កាលហ្នឹងខ្ញុំការនៅឆ្នាំ៧៨ហើយ ។

កុសលៈ	មកការនៅបាត់ដំបងនេះ?

ហមៈ	អត់ទេ ការនៅបុសតាផង់នេះ ការហើយមកបណ្តោយការឆ្នាំ៧៨ហ្នឹង ។

កុសលៈ	បុសតាផង់ហ្នឹងនៅណា?

ហមៈ	នៅខាងលិចព្រែកួច ។

កុសលៈ	នៅតាកែវហ្នឹង?

ហមៈ	បាទ!តាកែវ ។

កុសលៈ	ចឹងគ្រួសារលោកពូអ្នកតាកែវដែរ?

ហមៈ	គ្រួសារខ្ញុំនៅតាកែវដែរ ។

កុសលៈ	កាលហ្នឹងគេរៀបចំឲ្យកាលហ្នឹងលោកពូឬមួយយ៉ាងម៉េចពេលហ្នឹង?

ហមៈ	កាលហ្នឹងខាងអង្គការរៀបឲ្យ ខាងប្រធានរោងចក្រហ្នឹងគាត់រៀបឲ្យតែម្តង កាលហ្នឹងមាន ៩គូរ អត់មានបានឃើញគ្នាទេ ។

កុសលៈ	ចឹងនៅស្រឡាញ់គ្នារហូតដល់សព្វថ្ងៃ?

ហមៈ	ស្រឡាញ់គ្នាដល់សពថ្ងៃតែភាគច្រើនបែកទាំងអស់ តែខ្ញុំគិតឃើញថា ធម្មតាបងប្អូនគេមានស្រីប្រុសដូចគ្នាណាស់ កាលណាយើងបានគ្នាយើងលែងទៅវាមិនកើត ចឹងសុខចិត្តយករហូត ។

កុសលៈ	យើងកំសត់កំរកជាមួយគ្នា?

ហមៈ	បាទ ។

កុសលៈ	ចឹងខ្ញុំសរសើរសម័យនេះស្គាល់គ្នាហើយនៅតែបែកគ្នាទៀត?

ហមៈ ខ្លះគេចប់ទៅគេបែកគ្នាខ្ញុំអត់ទេ តែគ្រាន់ថាខ្ញុំកូនតិចជាងគេ ខ្ញុំកូនមានកូនបួននាក់ស្លាប់អស់ពីរនៅតែពីរ ។

កុសលៈ ស្លាប់ជំនាន់នោះដែរ?

ហមៈ អត់ទេ កូនខ្ញុំស្លាប់នៅនេះវាលេងគ្រាប់ ។

កុសលៈ ពេលហ្នឹងមីងនៅក្នុងទាហានជាមួយគ្នាឬមួយយ៉ាងម៉េច?

ហមៈ កាលនៅរោងចក្រ ។

កុសលៈ កាលនៅរោងចក្រឈើ?

ហមៈ អត់ទេ ខ្ញុំជាកម្មករហើយ ខ្ញុំនៅផ្នែកស៊ីវិល ។

កុសលៈ ហ៎ុយបានជួបគាត់ហើយគេរៀបចំឲ្យទៅ?

ហមៈ បាទ ។

កុសលៈ គាត់ទៅធ្វើជាកម្មករនៅកន្លែងហ្នឹងដែរ?

ហមៈ ប្រពន្ធខ្ញុំគាត់នៅកន្លែងដាំកប្បាស ។

កុសលៈ ហើយពីធីហ្នឹងយ៉ាងម៉េចដែលពីអាចរៀបរាប់បានទេថ្ងៃរៀបការហ្នឹង?

ហមៈ ថ្ងៃរៀបការគ្រាន់តែគណៈអធិបតេយ្យគេប្រាប់ថា ថ្ងៃនេះត្រូវរៀបការប៉ុន្មានគូរចឹងទៅណាស់ ឧទាហរណ៍១៥គូរចឹងគេរៀបតុឲ្យអង្គុយចឹងទៅជាជួរទៅ ហើយគាត់និយាយណែនាំខ្លះចឹងទៅណាស់ ។

កុសលៈ អ្នកណាគេជាអ្នកណែនាំ?

ហមៈ ប្រធានរោងចក្រហ្នឹងតែម្តង តែគាត់ស្លាប់អស់ហើយ គាត់ថាឲ្យចាប់ដៃគ្នាទៅយកគ្នាជាប្តីជាប្រពន្ធហើយខ្ញុំប្រពន្ធក៏អត់មានបានឃើញអីដែរ ខ្ញុំអត់មានបានឃើញទេ ខ្ញុំគិតតែអារឈើមួយថ្ងៃៗ អារទាំងយប់ទៀតពេលនោះ យប់ក៏អារដែរ គេឲ្យការភាគច្រើនមិនបានឃើញគ្នាទេ តែភាគច្រើនក៏លែងគ្នាចង់ទាំងអស់ដែរ គ្នាមិនសូវយល់ចិត្តគ្នាណាស់ ។

កុសលៈ បាទ ។

ហមៈ ហើយឲ្យប្តេជ្ញា ដល់ពេលនេះគេឲ្យប្តេជ្ញាចិត្តថា ឥឡូវយើងយល់យ៉ាងម៉េចយើងមានសណ្តានចិត្តយ៉ាងម៉េចដែលអង្គការរៀបឲ្យហ្នឹង គេសួរចឹង ចុះពេលនោះយ៉េងមានអីប្រកែកកើតសើច...យើងថាយកហើយប្តេជ្ញាថាយកគ្នាអស់មួយជីវិតតែប៉ុណ្ណឹង ចឹងណែនាំបន្តែមបន្ថិចអត់មានវិធីអីធំដុំទេ ក៏ចប់ទៅការពេលយប់ម៉ោង៧ មានថ្ងៃអី ។

កុសលៈ ហើយពេលហ្នឹងក៏បាននៅជាមួយគ្នាពូ?

ហមៈ ហើយគេចែកទៅតាមផ្ទះទៅ ហើយពេលនោះខ្ញុំមកបាត់ដំបងទៀតមក ។

កុសលៈ គាត់ត្រឡប់មកជាមយដែរ?

ហមៈ បាទ!ប្រពន្ធខ្ញុំមកជាមួយគ្នារហូត ។

កុសលៈ ចឹងការរៀបការហ្នឹង រៀបការនៅភូមិណាមានចាំទេ?

ហមៈ នៅបុសតាជង់ហ្នឹងតែម្តង ។

កុសលៈ នៅស្រុកអីកាលហ្នឹង?

ហមៈ បុសតាជង់ហ្នឹងមិនដឹងជាស្រុកអីកាលហ្នឹង នៅម្តុំស្រុកត្រពាំងអណ្តើកមិនដឹងស្រុកឈូក មិនដឹង ព្រោះអីខ្ញុំមិនសូវស្គាល់ផង ។

កុសលៈ ប្រហែលជាស្រុកឈូក?

ហមៈ បាទ ។

កុសលៈ ខេត្តកំពត?

ហមៈ បាទ!តាកែវមិនដឹង ។

កុសលៈ ចាំមើលខ្ញុំឆែកមើល ៗ?

ហមៈ បាទ ។

កុសលៈ ខ្ញុំថាតាកែវហើយ កាលហ្នឹងឆ្នាំ៧៨ហើយ?

ហមៈ ឆ្នាំ៧៨ ចុង៧៨ អះ!ចុង៧៧ ខែ៨ ឆ្នាំ៧៧ ។

កុសលៈ ចឹងពេលហ្នឹងកូនលោកពូកើតនៅណាមុនមកដល់បាត់ដំបងនេះ?

ហមៈ អត់ទេ ខ្ញុំកើតមកនៅតាមព្រំដែននេះហើយ ។

កុសលៈ ចឹងពេលត្រឡប់មកព្រំដែន?

ហមៈ បាទ!កើតឆ្នាំ៨១អីហើយ ។

កុសលៈ ចឹងកាលនៅបាត់ដំបងហ្នឹងគេឲ្យធ្វើអីដែលលោកពូ?

ហមៈ ខ្ញុំនៅប្រមូលឈើដាក់រោងចក្រ ។

កុសលៈ ចឹងជីវភាពក្នុងសហករណ៍កន្លែងពូនៅមានលក្ខណៈយ៉ាងម៉េចទៅនៅបាត់ដំបងវាមានលក្ខណៈយ៉ាប់ជាងមុនស្រួលជាងមុនឬមួយយ៉ាងម៉េច?

ហមៈ នៅក្នុងក្រុងនេះយើងអត់មានឃើញមនុស្សផង ។

កុសលៈ អត់មានមនុស្សទេ?

ហមៈ បាទ!អត់មានទេ មានតែផ្ទះនៅត្រឹង ៗ ហើយពួកខ្ញុំមកនៅក្នុងក្រុងហ្នឹងតែម្តងជិតវ៉ារថភ្លើង នៅផ្ទះថ្ម នៅតាមហ្នឹងតែយើងឃើញមានប្រជាជនធ្វើសប្បកម្មអីហ្នឹងណាស់ ខះដែល ចាស់ៗនៅហ្នឹង ។

កុសលៈ ចឹងតិចមែនទែន ស្វាត់?

ហមៈ ស្វាត់ជ្រាបតែម្ដង ។

កុសលៈ មានភ្លើងអគ្គីសនីមានអីទេ?

ហមៈ អត់ទេ ស្វាត់ឲ្យជ្រាបតែម្ដងហើយយប់ឡើងយើងយាមចឹងទៅណាស់ យាមការធម្មតា ខ្លាចមានអ្នកលួចអ្នកអីណាស់ ស្វាត់ជ្រាបអត់មានអីទេ កន្លែងពួកខ្ញុំហ្នឹងមានម៉ាស៊ីនអារឈើពីរគ្រឿង ហើយឡានសម្រាប់យកឈើមកពីព្រៃហើយជាងធ្វើឡានធ្វើអីហ្នឹងមួយក្រុមតែប៉ុណ្ណឹងទេ ។

កុសលៈ ចឹងក្រោយមកទៀត មានផ្លាស់មកទៀតទេ?

ហមៈ ក្រោយមកទៀតមកមានផ្លាស់មកទៀតឆ្នាំ៧៨ហ្នឹង ខ្ញុំចេញមកទៀតហើយពេលវៀតណាមយួនចូលមកហ្នឹង ។

កុសលៈ ចេញទៅណា?

ហមៈ មកខាងសំឡូត ចេញមកសំឡូតមកថៃបណ្ដោយចូលមកត្រាត ។

កុសលៈ ចឹងពេលឆ្នាំ៧៩ហ្នឹងមកនៅណា មកនៅភ្នំដងរែកនេះ?

ហមៈ បាទ!នៅភ្នំដងរែក ។

កុសលៈ ពេលហ្នឹងចូលទាហានទៀតឬមួយយ៉ាងម៉េច?

ហមៈ អត់ទេ មកដល់នៅនេះមានរោងចក្រនៅនេះទៀត គ្រប់គ្រងរោងចក្រហ្នឹងទៀត ។

កុសលៈ អារឈើ?

ហមៈ បាទ ។

កុសលៈ ចុះគេថាជំនាន់ហ្នឹងលុយដែលធ្វើការតស៊ូ តា ម៉ុក បានមកពីការអារឈើហ្នឹងមែនទេ?

ហមៈ ឈើហ្នឹងដឹកនាំទៅថៃ ។

កុសលៈ ចឹងឈើដឹកនាំទៅថៃច្រើនទេ?

ហមៈ ឈើដឹកនាំចេញទៅថៃ មានទៅមែនហើយខ្លះនោះអារឈើធ្វើផ្ទះឲ្យប្រជាជន ។

កុសលៈ ចឹងលុយកាក់បានមកពីណាជាអ្នកកាន់?

ហមៈ ខ្ញុំមិនសូវដឹងដែរ ។

កុសលៈ តា នៅ ជាគាត់ជាអ្នកកាន់លុយកាក់ភស្ដុភា?

ហមៈ បាទ!ខ្ញុំមិនសូវដឹងដែលមិនដឹងជានរណា ខ្ញុំនៅក្រោមនេះ នៅធ្វើការរោងចក្រ ។

កុសលៈ រោងចក្រអាឈើនៅត្រង់ណាលោកពូ?

ហមៈ នៅជំវត្តយើងនេះ ។

កុសលៈ ដីវត្តនេះ?

ហមៈ បាទ ។

កុសលៈ ហើយឈើយើងយកពីក្នុងមក?

ហមៈ ឈើយកមកពីក្នុងព្រៃ ។

កុសលៈ តែខ្ញុំឮថាវៀតណាមវាចូលមកច្រើនមែនទេ ចូលមកតំបន់នេះច្រើន ជំនាន់៨០ជាង ជំនាន់៨២-៨៣-៨៤អីវៀតណាមចូលមកច្រើនតំបន់នេះ កងទ័ពវៀតណាមចូលមកដល់ជើងភ្នំនេះមែនមិនមែន ចឹងរោងចក្រអាឈេអីយ៉ាងម៉េចទៅកាលហ្នឹង?

ហមៈ ព្រោះវាវៃអត់មានដុតទេ កាលហ្នឹង វាវៃអត់មានដុតទេ វាវៃហើយមានផ្ទះណាឆេះៗទៅ យើងទៅលើចឹងពេលវាទៅវិញយើងចុះមកវិញ ។

កុសលៈ ចឹងទៅមកៗចឹង?

ហមៈ ទៅមកចឹង ។

កុសលៈ កាលរស់នៅក្នុងពេលហ្នឹងមានការលំបាកយ៉ាងម៉េចទៅលោកពូ ប្រឈមមុខជាមួយពួកវៀតណាមចូលមក ទំនាក់ទំនងយើងនៅគាបសង្កត់ខាងថៃនៅខាងនោះ?

ហមៈ យើងលំបាកមែនទែនដែលហ្នឹង ព្រោះយើងមានការខូះខាតបន្តិចយើងរត់បន្តិចយើងឆេះផ្ទះអស់ចឹងទៅណាស់ លំបាកយកមែនទែនតែម្តង ផ្ទះខ្ញុំហ្នឹងឆេះអស់ហើយមិនដឹងជាប៉ុន្មានដងទេ ឲ្យតែវៃម្តងឆេះម្តងៗមកវិញអស់យើងចាប់ផ្តើមធ្វើទៀតទៅ ។

កុសលៈ ចឹងផ្ទះចាស់ពូនៅម្តុំហ្នឹងដែរ?

ហមៈ បាទ!នៅម្តុំហ្នឹងដែរ នៅក្រោយនេះ ។

កុសលៈ ចឹងលោកពូមានបាត់បង់កូនលោកពូពីរនាក់ កាលឆ្នាំ៨០ជាង?

ហមៈ កូនម្នាក់ស្លាប់ដោយសារលេងគ្រាប់ ពេលឃ្វាលគោដល់ចឹងវាអុកគ្រាប់លេងក៏ផ្ទុះទៅនៅក្បែរផ្លូវហ្នឹង ខ្ទិចអស់ស្លាប់មួយកូនប្រុស ហើយមួយទៀតយើងភាសខ្លួនទៅនៅដូណយហ្នឹង ។

កុសលៈ នៅថៃ?

ហមៈ បាទ!នៅដូណយនៅថៃហ្នឹងភ្នំលើនេះ វាកើតមកអស់រស់ស្លាប់កូនប្រុសខ្ញុំអត់មានទៅពេទ្យផងកាលនោះមិនដឹងជាយ៉ាងណា ដូចថាខ្ញុំមិនចង់ទៅពេទ្យ កាលនោះមានពេទ្យបារាំងមកច្រើនមែនទែន ។

កុសលៈ ពេទ្យអន្តរជាតិគេចុះមកជួយ?

ហមៈ ពេទ្យអន្តរជាតិតែម្តង តែខ្ញុំមិនទៅនៅប្រហែលជា១០០ម៉ែត្រ ឆ្នមគេថាកើតៗក៏អត់ចឹងសម្រាប់កូនប្រុសអស់រលីងតែម្តង ។

កុសលៈ ចឹងនៅសល់តែកូនស្រី?

ហមៈ ហ្នឹងហើយនៅកូនច្បងមួយស្រី កូនពៅមួយស្រីនៅពីរនាក់ ។

កុសលៈ រៀបការហើយអស់?

ហមៈ នៅមួយអូន នៅពៅមួយអាយុ៩ឆ្នាំ ។

កុសលៈ តូចជាងគេ៩ឆ្នាំ?

ហមៈ ៩ឆ្នាំ ខ្ញុំកូនបួននាក់ ។

កុសលៈ ខ្ញុំស្តាប់សាច់រឿងលោកពូទៅឃើញថា យលច្រើនលោកពូឆ្លងកាត់មកវាច្រើនដែរ ចឹងគ្រួសារសាច់ញាតិផ្សេងៗមានបាត់បង់ច្រើនទេ តើឪពុករបស់ពូទៅណា ឪពុកបង្កើតនៅរស់ទេ?

ហមៈ ឪពុកខ្ញុំស្លាប់ ។

កុសលៈ ម្តាយ?

ហមៈ ម្តាយនៅ ។

កុសលៈ ឥឡូវគាត់នៅណា?

ហមៈ គាត់នៅកំពង់ស្ពឺ ភូមិសំព័រហ្នឹងដដែល ។

កុសលៈ ចឹងនៅដដែលនៅកំពង់ស្ពឺ?

ហមៈ បាទ!ខ្ញុំទើបមកពីលេងគាត់ដែលហ្នឹង គាត់ចាស់ហើយគាត់វង្វេងអស់ហើយ ធ្លាក់ពីលើផ្ទះផង ។

កុសលៈ ចឹងបងប្អូនលោកពូ?

ហមៈ បងប្អូនខ្ញុំនៅទាំងអស់ ។

កុសលៈ នៅកំពង់ស្ពឺហ្នឹងដែរ?

ហមៈ បាទ!នៅមូលគ្នាជាមួយម្តាយហ្នឹងមកតែខ្ញុំមក ។

កុសលៈ ចឹងជំនាន់បីឆ្នាំគាត់នៅកំពង់ស្ពឺហ្នឹងដែលឬមួយយ៉ាងម៉េចឬមានជម្លៀសទៅណាទៅណីដែលឬអត់ទេ?

ហមៈ គាត់រត់ដែលតែគាត់រត់ជិតៗហ្នឹង គាត់រត់ហើយគាត់មកស្រុកភូមិគាត់វិញ ។

កុសលៈ ចឹងពូមានដែលបានជួបទេ មិនដែលបានជួបបងប្អូនអីសោះក្នុងរយៈពេលបីឆ្នាំ៨ខែ?

ហមៈ កាលហ្នឹងអត់មានបានជួបទាំងអស់ ។

កុសលៈ ចឹងចេញពី៧៣ហ្នឹងមករហូតមិនដែលបានជួបទេ?

ហមៈ បាទ!មិនដែលបានជួបទេ ។

កុសលៈ ចឹងបើគិតទៅវិញក្នុងជីវិតរបស់ពូ តើអ្វីទៅដែលពូនៅចងចាំជានិច្ចមិនអាចបំភ្លេចបាននៅចាំរហូត?

ហមៈ ចងចាំជានិច្ចខ្ញុំឃើញថា លំបាកណាស់សម្រាប់ជីវិតហើយកើតមកជួបប្រទះសង្គ្រាមសឹងថា ផ្តាំកូនចៅទៅថ្ងៃមុខទៀតកុំឲ្យមានសង្គ្រាម ព្រោះលំបាកណាស់ លំបាកមែនទែនទី១ ព្រាត់ប្រាស់ឪពុកម្តាយញាតិមិត្តទាំងអសទី២ទៀតជីវិតយើងប្រឈមនិងថ្ងៃស្លាប់រហូត ប៉ុន្តែដល់ពេលយើងបានរស់មកអាហ្នឹងដូចចាស់ពីដើមថា អាហ្នឹងទឹកដោះម្តាយថ្ងៃបានរស់មក ប្រឈមនិងការលំបាកហើយទី២ទៀត ធ្វើឲ្យប្រជាពលរដ្ឋមានជីវភាពក្រីក្រលំបាកសង្គ្រាមពេក យើងមិនចង់ឲ្យមានទេ ។

កុសលៈ បាទ!ចឹងមកដល់ពេលបច្ចុប្បន្នលោកពូឆ្លងកាត់ទៅលោកពូឆ្លងកាត់របបទាំងអស់ហ្នឹងមកតើលោកពូយល់ថា ខ្លួនឯងជាជនរងគ្រោះឬជាអ្នកបដិវត្តម្នាក់ដែលស្រឡាញ់ប្រទេសជាតិឬក៏ថាទាំងពីរ?

ហមៈ ខ្ញុំថាពេលនោះយើងស្រឡាញ់ជាតិ យើងស្រឡាញ់ជាតិបានយើងខំតស៊ូដើម្បីសុភមង្គលដើម្បីប្រជាជនក្រីក្រឲ្យមានឡើង ។

កុសលៈ បាទ!ចឹងកងអំឡុងពេលឆ្នាំ៨០ដល់សមាហរណ៍កម្ម៩៨ ពេលហ្នឹងលោកពូនៅអាឈើរហូតមក?

ហមៈ ពេលហ្នឹងនៅហ្នឹងរហូត នៅអាឈើរហូត ។

កុសលៈ ចឹងកាលធ្វើសមាហរណ៍កម្មហ្នឹងពូចូលមកជាមួយក្រុមមុនដំបូងឬក៏ក្រោយ ចូលមុនឬចូលក្រោយ?

ហមៈ គេចូលមុនខ្ញុំនៅក្រុមក្រោយ អាលែងនៅជំរំ ។

កុសលៈ ចឹងមិនមែនមកជាមួយ បង ដាន់ ណា ជាមួយ យឹម ពឹម មែនទេ?

ហមៈ អត់ទេ ។

កុសលៈ ចង់មកក្រោយទេ?

ហមៈ បាទ ។

កុសលៈ ហើយយ៉ាងម៉េចបានជាគាត់មិនមកមុន?

ហមៈ មេៗមកមុន ។

កុសលៈ បាទ!យ៉ាងម៉េចបានជាមិនផ្តាច់ខ្លួនមកមុន?

ហមៈ កាលហ្នឹងខ្ញុំមិនយល់ដែលខ្ញុំនៅក្រោយខ្ញុំនៅរោងចក្រ គ្រាន់ថាសម្រាប់ទាហាននៅជួរមុខ ហើយពួកខ្ញុំនៅជួរក្រោយ ចឹងមិនដឹងថាគាត់បទបែនសភាពការណ៍យ៉ាងម៉េចខ្ញុំមិនយល់ដែរ ដលប្រជាជនគ្រាប់ផ្លោងដឹង១មករត់បណ្តោយ រត់ឡើងភ្នំបណ្តោយយើងមិនដឹងជាមានជម្រើសទៅណាទៀត រត់យកម៉ារូបខ្លួនសិន ។

កុសលៈ ចឹងពេលពូរដ្ឋាភិបាលប្រកាសសូមឲ្យបងប្អូនទាំងអស់ចូលមក ពេលហ្នឹងពូមានអារម្មណ៍ជឿទុកចិត្តទេពេលហ្នឹង មានអារម្មណ៍យ៉ាងម៉េចខ្លះពេលហ្នឹង?

ហមៈ ខ្ញុំគិតថា តាមការលំបាកកន្លងមកខ្ញុំគិតថា គ្មានជម្រើសទេ ជម្រើសគ្មានទេ មានតែរដ្ឋាភិបាលមួយគត់ ។

កុសលៈ មានតែមួយគត់ដែលត្រូវត្រឡប់មកវិញ?

ហមៈ ដែលត្រូវត្រឡប់មកវិញ ។

កុសលៈ តែពេលហ្នឹងមានបារម្ភណ៍ទេ?

ហមៈ ការពិតទៅយើងនៅមានចិត្តបារម្ភណ៍ដែលណាស់ មិនដឹងជាយ៉ាងម៉េច តែចិត្តត្រូវតែមកចឹងតែម្តងមករកជាតិមករកប្រទេសវិញ មិនដឹងជាទៅណាទេ មានតែផ្សះផ្សារជាមួយរដ្ឋាភិបាលមកទឹករបស់យើងភូមិរបស់យើងវិញ ។

កុសលៈ ចឹងក្រោយមកហេតុអីបានជាគេជ្រើសពូឲ្យធ្វើប្រធានភូមិ?

ហមៈ ប្រជាជនគាត់បោះឆ្នោតឲ្យ ។

កុសលៈ គេចាត់តាំងឲ្យ?

ហមៈ អត់ទេ ប្រជាជនក្នុងភូមិហ្នឹងតែម្តង គាត់ជ្រើសរើសឲ្យ ។

កុសលៈ មានទំនប់ចិត្តលើលោកពូ?

ហមៈ បាទ ។

កុសលៈ ចឹងមកដល់ថ្ងៃនេះលោកពូថា មានម្ចាស់ការលើខ្លួនឯង ដូចថាលែងមានការភិតភ័យលែងមានការបារម្ភណ៍ពីរដ្ឋាភិបាលបច្ចុប្បន្នដូចថាពូទុកចិត្ត?

ហមៈ ខ្ញុំមានទំនុកចិត្ត១០០ភាគរយ មកដល់បច្ចុប្បន្ននេះខ្ញុំមានការទុកចិត្តលើរដ្ឋាភិបាលទាំងស្រុង ។

កុសលៈ បាទ ។

ហមៈ គិតថាមិនមានបញ្ហាអីទៀតទេ ។

កុសលៈ ចឹងការសាមគ្គីភាពនៅក្នុងភូមិឃុំយើងយ៉ាងម៉េចដែរ?

ហមៈ ខ្ញុំឃើញថា ការសាមគ្គីនៅក្នុងភូមិឃុំរបស់យើងប្រហាក់ប្រហែលគ្នា ខ្ញុំជឿជាក់លើរដ្ឋាភិបាលអត់មានភ័យបារម្ភណ៍អីទៀតទេ ។

កុសលៈ បាទ ។

ហមៈ ខិតខំរួបរួមគ្នាអភិវឌ្ឍន៍ ។

កុសលៈ ចឹងលោកពូទុកចិត្តថា មានម្ចាស់ការលើខ្លួនឯងមុនច្រើនក្នុងការគ្រប់គ្រងគ្រួសារ ក្នុងការដឹកនាំភូមិអី ពូមានទំនុកចិត្តលើរដ្ឋាភិបាលច្រើនពីទី១ដល់៥មានច្រើនឬតិច?

ហមៈ ខ្ញុំថាអ៊ីៗក៏ដោយវាត្រូវមានការណែនាំឬក៏វគ្គបណ្តុះបណ្តាលអ៊ីមួយក្នុងការដឹកនាំបានយើងធ្វើទៅកើត ។

កុសលៈ បាទ ។

ហមៈ យើងមិនអាចម្ចាស់ខ្លួនឯងបានទេ ផ្នែកកសិកម្មក៏ដោយផ្នែកសុខភាពអនាម័យ ការអប់រំទាំងអស់ហ្នឹង ។

កុសលៈ ទាល់តែមានការអប់រំពីថ្នាក់លើមក?

ហមៈ បាទ ។

កុសលៈ ចង់និយាយចឹង មានថ្នាក់ដឹកនាំឲ្យធ្វើ?

ហមៈ ចឹងទាល់តែមានការអប់រំមកណាស់ ។

កុសលៈ ចឹងលោកពូជាថ្នាក់ដឹកនាំតាមដ្ឋានដែលតែងគោរពតាមថ្នាក់លើមកចឹងមែនពូ?

ហមៈ បាទ!គោរពតាមការណែនាំ ។

កុសលៈ បាទ!ខ្ញុំសួរមួយសំនួរសំខាន់មួយទៀត ធ្វើមេចទៅឲ្យមានការផ្សះផ្សារជាតិ ដើម្បីសន្តិភាពដើម្បីឲ្យមានការផ្សះផ្សារជាតិ បើតាមលោកពូឆ្លងកាត់មក?

ហមៈ ដើម្បីឲ្យមានការផ្សះផ្សារជាតិយើងខ្ញុំពិនិត្យថា បើពាររំងាប់បានដោយការមិនចងពារ បើយើងចងពារខ្ញុំគិតថា អត់ចប់ទេ គ្រាន់ថាមនុស្សវាភ័យខ្លាចទី១ ទី២ទៀតយើងអត់មានធ្វើការរកស៊ីអីចឹងយើងគិតស្មុគស្មាញ ។

កុសលៈ បាទ ។

ហមៈ គិតពីបញ្ហាពីនេះពីនោះ តែបើដូចបច្ចុប្បន្ននេះជ្រះស្រឡះតែម្តងហើយខ្ញុំគិតថា មិនមានភ័យអីទៀតទេ ។

កុសលៈ បាទ!ចឹងប្រជាជនក្នុងភូមិយើងយ៉ាងម៉េចដែលលោកពូ នៅស្រះឈូកហ្នឹង?

ហមៈ ប្រជាជនក៏គាត់ថា ការផ្សះផ្សារជាតិហ្នឹងជាធំ គាត់មិនចង់មានសង្គ្រាមគាត់មិនចង់មានការ ។

កុសលៈ កាត់ទោសបន្តទៀត?

ហមៈ បាទ ។

កុសលៈ ចំពោះអ្នកខ្លះថា ដើម្បីឲ្យមានសន្តិភាពលុះត្រាឲ្យមានតុលាការ រាល់ថ្ងៃហ្នឹងរដ្ឋាភិបាលនិងតុលាការអន្តរជាតិគេកំពង់តែធ្វើការនៅភ្នំពេញ ពូមានបានទៅចូលរួមទេ?

ហមៈ ខ្ញុំអត់មានបានទៅផងកាលនោះ ខ្ញុំឈឺ ។

កុសលៈ កាលហ្នឹងគេអញ្ជើញប្រធានភូមិទាំងអស់?

ហមៈ បាទ!គេអញ្ជើញតែខ្ញុំឈឺ ។

កុសលៈ ពូយល់ថា តុលាការគេធ្វើអស់លុយរាប់លានហ្នឹងមានសារសំខាន់ប៉ុណ្ណាទៅដល់ប្រជាជនយើងឬក៏មិនមានទាល់តែសោះវាអស់លុយជាង១០០លានហើយ?

ហមៈ ខ្ញុំគិតថា ប្រយោជន៍មានមិនអត់ទេ វាពិតជាមានសម្រាប់អ្នករងគ្រោះ គាត់មានការលំបាកកន្លងមកណាស់ ឬមានគេកាប់សម្លាប់គឺពិតជាមានប្រយោជន៍ ប៉ុន្តែសម្រាប់ទៅអនាគតទៀត ខ្ញុំគិតថា ការផ្សះផ្សារជារឿងធំតែម្តង ។

កុសលៈ ចឹងយើងគួតែបំភ្លេចចោលទៅនៅអ្វីដែលវាកើតឡើងកន្លងផុតទៅហើយ?

ហមៈ បាទ ។

កុសលៈ ចឹងការដែលអត់ខិនទោស ដូចថាសង្គមយើងទាមទារឲ្យមានការអត់ខិនទោសគ្នាទៅវិញទៅមកដើម្បីការផ្សះផ្សារជាតិ ការទប់កំហឹងអីជាដើម?

ហមៈ អាហ្នឹងតាមខ្ញុំយល់គឺថា ការផ្សះផ្សារជាតិទាល់តែមានការអត់ខិនឲ្យគ្នាបានៗ បើយើងមិនអត់ខិនឲ្យគ្នាអាហ្នឹងយើងមិនមានការផ្សះផ្សារគ្នាបានទេ ។

កុសលៈ បាទ!ចឹងយើងគួរតែរំលឹកឡើងវិញឬយើងគួរតែបំភ្លេចចោលទៅរឿងអ្វីដែលបានកើតឡើង ខ្ញុំថាចំណុចមួយហ្នឹងសំខាន់ដែរ ព្រោះសង្គមផ្សេងៗទៀតដូចជានៅប្រទេសស៊ីឡេប្រទេសឈីលីហ្នឹងធ្លាប់មានដូចគ្នាដែរ នៅប្រទេសរ៉ូវ៉ាន់ដា នៅប្រទេសអេស្បាញក៏ចឹងធ្លាប់មានចឹងដែរ របបមុននិងរបបក្រោយមានការអត់ខិនទោសគ្នា ពីព្រោះថា តែងតែមានខុសនិងត្រូវវាមានសាច់រឿងពីរអ្នកក្នុងយកមកពីក្នុងអ្នកក្រោយកមកពីក្រៅ ដូច្នេះវាទាក់ទងទី១ ទាក់ទងនិងថា ស្វែងយល់ពីគ្នាទៅវិញទៅមក ចង់និយាយថា អ្នកក្នុងត្រូវពីអ្នកក្រៅ អ្នកពីក្រៅស្វែងយល់ពីអ្នកក្នុង យល់ពីផលលំបាករបស់អ្នកក្នុង អ្នកក្នុងត្រូវយល់ពីផលលំបាកពីការលំបាកការតស៊ូមកពីខាងក្រៅ ដូច្នេះខ្ញុំចង់និយាយថា ការផ្សះផ្សារហ្នឹងវាមានលក្ខណៈស្មុគស្មាញជាងតុលាការទៅទៀត តុលាការហ្នឹងមិនគ្រប់គ្រាន់ឲ្យប្រទេសយើងហ្នឹងមានការផ្សះផ្សារទេ ចឹងខ្ញុំចង់និយាយថា ឲ្យមានការអត់ខិនឲ្យគ្នាទោស

គ្នាទៅវិញទៅមក មានការស្វែងយល់ចងក្រងជាកំរងប្រវត្តិសាស្ត្រយល់គ្នាទៅវិញទៅមក ទាំងខាងក្នុងទាំងខាងក្រៅណាស់ ដូច្នេះក្នុងចំណោមទាំងអស់ហ្នឹង ពូយល់ថាប្រទេសយើងត្រូវការអ្វីខ្លាំងជាងគេបំផុតដើម្បីឲ្យមានការផ្សះផ្សារ?

ហម: ខ្ញុំគិតថា តុលាការការកាត់ទោស គឺត្រូវតែកាត់ចំពោះអ្នកដឹកនាំកំពូល អ្នកដឹកនាំជាន់ខ្ពស់បំផុតថ្នាក់ជាតិ ។

កុសល: បាទ ។

ហម: ថ្នាក់ជាតិកម្ពុជាប្រជាធិបតេយ្យត្រូវតែកាត់ហើយព្រោះគាត់បានធ្វើឲ្យស្លាប់ប្រជាពលរដ្ឋច្រើនណាស់ ការលំបាកគាត់ត្រូវតែទទួលខុសត្រូវ ប៉ុន្តែមិនត្រូវបេះតែកាត់០១-០២-០៣-០៤ បេះតែបន្តទៅទៀតក៏វាមិនល្អដែរ ចង់និយាយថា យើងកាត់តែអ្នកដឹកនាំកំពូលហ្នឹង បានន័យថាប្រជាពលរដ្ឋសម័យហ្នឹងដូចខ្ញុំជំរាបនិងថា គាត់មិនដឹងអីទេ គាត់បេះតែធ្វើតាមបញ្ជាគេទៅ បើកាត់ដល់អាក្រោមទៀត ហាក់បីដូចជាចងពារមិនចប់ទេ ។

កុសល: បាទ!វាប៉ះពាល់ដល់សន្តិភាពនិងការផ្សះផ្សារជាតិ?

ហម: បាទ!អត់ចប់ទេ កាត់០១-០២ហ្នឹងសមរម្យហើយ សមរម្យល្អណាស់ខ្ញុំពេញចិត្ត ។

កុសល: ចឹងលោកពូយល់ថាអ្នកដែលធ្វើតាមបញ្ជាគេ គ្នាក៏មិនដឹងដែលធ្វើតាមបញ្ជាគេទេ មិនចឹងណែស ចឹងមិនគួរណាយកមកកាត់ទោសមិនចឹង?

ហម: បាទ ។

កុសល: ចឹងបើសិនជាលោកពូគាំទ្រថា យកពួកគាត់មកកាត់ទោសឬកាត់ទោសកំរិតស្រាលធ្ងន់ឬក៏កំរិតណា?

ហម: អាហ្នឹងមតិវិធីខ្ញុំអត់យល់ដែលអូន ស្រេចលើតុលាការទេ ខ្ញុំអត់យល់ដែរ ។

កុសល: ចឹងតុលាការហ្នឹងពូថាវាសំខាន់ដែរ តែវាមិនជាសំខាន់ប៉ុន្មានទេ បើសិនជាកាត់វាអាចប៉ះពាល់បើសិនជាកាត់ទោសលើសពី០២ ចឹងពូណែសចង់បញ្ជាក់កន្លែងហ្នឹង ចុះអាចធ្វើឲ្យថា តុលាការហ្នឹងអាចធ្វើឲ្យទប់ស្កាត់នូវអំពើរបបបីឆ្នាំហ្នឹងកុំឲ្យកើតឡើងម្តងទៀត ពូជឿទេ ពូជឿថា តុលាការហ្នឹងអាចមានលទ្ធិភាពដល់ប៉ុណ្ណឹង ទប់ស្កាត់អំពើហ្នឹងមិនឲ្យកើតឡើងទៀតឬក៏សំនួរមួយទៀត ពូគិតថា តុលាការហ្នឹងបម្រើផលប្រយោជន៍ឲ្យអ្នកណារាល់ថ្ងៃហ្នឹង ធ្វើអស់រាប់រយលានហ្នឹង?

ហម: ខ្ញុំគិតថា សម្រាប់ប្រជាពលរដ្ឋខ្មែរទូទៅដែលបានមើលទូរទស្សន៍ឬបានស្តាប់តាមវិទ្យុអីហ្នឹង គាត់យល់ហើយគាត់ថា សម្រាប់អ្នកប្រព្រឹត្តិមិនល្អគឺប្រជាជនគាត់អត់មានគាំទ្រទេ

ហើយពិសេសថ្នាក់ដឹកនាំដូចអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលបានឯកភាពថ្នាក់ដឹកនាំកាន់ប្រទេសនោះ ។

កុសលៈ ចឹងពូមានការសប្បាយចិត្តទេ ដូចថាគេធ្វើហ្នឹង គេធ្វើក្នុងប្រទេសយើង ប្រទេសកម្ពុជាយើងហើយមានខ្មែរយើងចូលរួម?

ហមៈ ខ្ញុំសប្បាយចិត្តណាស់ ព្រោះមានសាលាក្ដីកាត់ទោស ។

កុសលៈ បាទ ។

ហមៈ ធ្វើឲ្យកូនចៅជំនាន់ក្រោយឃើញកុំយកគំរូតាមណាស់ ។

កុសលៈ បាទ ។

ហមៈ យើងបានកាត់ទោសអ្នកដែលប្រព្រឹត្តខុស អ្នកល្អគាត់និងអាចសប្បាយចិត្ត ប្រជាពលរដ្ឋគាត់សប្បាយចិត្តយើងបានឃើញអ្នកខុសអ្នកត្រូវ ។

កុសលៈ ចឹងខ្ញុំត្រឡប់មករដ្ឋាភិបាលបច្ចុប្បន្នវិញ ការអភិវឌ្ឍន៍ភូមិឃុំវិញពូ ខ្ញុំសង្កេតឃើញមួយនៅអន្លង់វែងជាទូទៅ ពួកអតីតទោះបីគាត់ពិការក៏ដោយតែគាត់មិនទំលាប់សុំទានគេឃើញគាត់ធ្វើចម្ការច្រើនប្រែងហេតុអី ហេតុអីពីព្រោះអ្នកនៅស្រុកផ្សេងៗមានអ្នកសុំទានច្រើនណាស់ ប៉ុន្តែនៅនេះហេតុអីទម្លាប់និងចេញពីណាមកឫសគល់ពីណាមក?

ហមៈ ការពិតទៅយើងជាទំលាប់ការរស់នៅតាមព្រំដែនក្ដីគឺយើងមានទំលាប់ធ្វើស្រែធ្វើចម្ការហើយថា សេដ្ឋកិច្ចមានឫសមានគល់នៅលើដីតែម្ដង ។

កុសលៈ ចឹងសេដ្ឋកិច្ចមានឫសមានគល់?

ហមៈ បាទ!សេដ្ឋកិច្ចមានឫសមានគល់ គឺមានដីមានទឹក គាត់អាចរស់បានហើយ ព្រោះគាត់ធ្វើស្រែធ្វើចម្ការដាំដុះ ចឹងគាត់រស់តែម្ដង ។

កុសលៈ ចឹងទំលាប់ពីមុនមក?

ហមៈ ពីមុនមកក៏ចឹង ។

កុសលៈ ពេលដែល ប៉ុល ពត គាត់នៅរស់គាត់បង្រៀនចឹងគាត់ប្រាប់ឲ្យយើងមានសេដ្ឋកិច្ចឫសគល់ពីមុនមក ខ្ញុំគិតថា ជាទំលាប់ខុសពីស្រុកគេផ្សេង?

ហមៈ បាទ ។

កុសលៈ ខ្ញុំឃើញការដាំដុះនៅទីនេះមានខុសអភិវឌ្ឍន៍ទៅជាលឿនជាងគេ បន្ទាប់ពីសមាហរណ៍កម្មមកជិត១០ឆ្នាំជាងប៉ុណ្ណឹង ប៉ុន្តែសន្ទុះការអភិវឌ្ឍន៍ហ្នឹងលឿនជាងគេ ត្រង់ចំណុចនេះសុំលោកពូរៀបរាប់ឲ្យបានច្បាស់ថា តើសេដ្ឋកិច្ចឫសគល់ហ្នឹងវាយ៉ាងម៉េចខ្លះហើយវាជះឥទ្ធិពលយ៉ាងណាខ្លះដល់សង្គម ដល់ការអភិវឌ្ឍន៍ភូមិឃុំ?

ហមៈ ចង់និយាយថា ប្រជាពលរដ្ឋទាំងអស់សម្រាប់មូលដ្ឋានជាកសិករ៩៥ឬ៩៨ភាគរយគាត់ជាកសករសុទ្ធសាធហើយពឹងផ្អែកលើដំណាំកសិកម្មជាមូលដ្ឋាន ចឹងគាត់ត្រូវការដាំដុះត្រូវការចិញ្ចឹមសត្វនៅក្នុងភូមិដ្ឋានរបស់គាត់ ដើម្បីយកភោគផលហ្នឹងបម្រើឲ្យជីវភាពរបស់គាត់ឲ្យបានហូបបានចុកបានលក់ដូរបានដោះស្រាយជីវភាពរបស់គាត់ចឹង គាត់មានជីវភាពធូរធារហើយដល់សមាហរណកម្មមកទៀត រដ្ឋាភិបាលមានវគ្គបណ្តុះបណ្តាលតាមរយៈអង្គការក្តីឬតាមរដ្ឋអំណាចក្តីគឺយើងផ្តោតលើសេដ្ឋកិច្ចជាសំខាន់ សេដ្ឋកិច្ចកកសិកម្មប្អូន ។

កុសលៈ បាទ ។

ហមៈ ចឹងប្រជាជនគាត់អត់លំបាកទេ គាត់ពេញចិត្តហ្នឹងធ្វើតែម្តងធ្វើលើទឹកដីរបស់គាត់ ។

កុសលៈ ចុះការបញ្រ្ជាបគោលនយោបាយរដ្ឋាភិបាលមកតាមតំបន់ភូមិឃុំលោកពូថាបានជិតដល់មានលក្ខណៈមួយថា ពេញលេញហើយឬនៅក៏មានការខ្វះខាតអីខ្វះ?

ហមៈ ខ្ញុំគិតថា បញ្រ្ជាបរបស់រដ្ឋាភិបាលឬតាមរយៈអង្គការផ្សេងៗគឺយើងបានបញ្រ្ជាបរហូតតាំងពីសមាហរណ៍កម្មមក ប៉ុន្តែសម្រាប់ការចាប់បានរបស់ប្រជាពលរដ្ឋដូចជាផ្នែកកសិកម្មក្តីយើងមានយើងណែនាំគាត់ឲ្យជ្រើសរើសពូជ ធ្វើស្រែមានភ្ជួបរាស់ដី ការប្រើប្រាស់ជីអ៊ីៗទាំងអស់ហ្នឹង គាត់បានបណ្តុះបណ្តាលមានការអប់រំជាការប្រជុំជាអីឡើងដើម្បីធ្វើឲ្យគាត់យល់ ។

កុសលៈ បាទ ។

ហមៈ តែគ្រាន់តែចុះអភិវឌ្ឍន៍ទៅវាអត់បានសមស្របតាមគោលដៅទេ ។

កុសលៈ បាទ ។

ហមៈ ពីព្រោះគាត់ទីពឹងលុយដែរ ចង់និយាយចឹង កាលសម័យនោះយើងអត់លុយយើងខំ តែសម័យឥឡូវយើងមានលុយយើងពឹងផ្អែកលើលុយខ្វះ ប៉ុន្តែត្រង់ថា សេដ្ឋកិច្ចមានឫសមានគល់ចឹងគឺជាមូលដ្ឋានសម្រាប់មនុស្សនៅក្នុងមូលដ្ឋានយើងនេះ ភាគច្រើនជាដំណាំកសិកម្មដាំដំឡូងអីទាំងអស់ហ្នឹងទេ ។

កុសលៈ ចឹងទំលាប់របស់គាត់ពីមុនមកចឹង រឿងការសុំទានអីនេះជារឿងមួយខុសទៅនិងគោលការណ៍?

ហមៈ បាទ!គាត់មិនសុំទេ ទោះបីគាត់ជិះរទេះទាំងពីរក៏ដោយក៏គាត់កាប់ដីដែរ ដាំដំឡូងអីបានលក់ ។

កុសលៈ ហេតុអីបានចឹង ការសុំទានគេហ្នឹងវា ខ្ញុំមិនដឹងជារកពាក្យយ៉ាងម៉េចនិយាយឲ្យត្រូវ ដូចថា អ៊ីគាត់មិនទទួលយកបានតែម្តងដោយសារគាត់និងបានបណ្តុះបណ្តាលរៀនពីមុនមកថា យើងមិនត្រូវសុំទានគេ?

ហមៈ បាទ!មែនហើយ ។

កុសលៈ ឬទាក់ទងនិងព្រះពុទ្ធសាសនាឬការបង្រៀនជំនាន់មុនសមាហរណ៍កម្មទៅទៀត?

ហមៈ តាមពិតទៅសមាហរណ៍កម្មយើងមានគោលការណ៍សេដ្ឋកិច្ចមានបុសមានគល់ហ្នឹងយើង មិនធ្វើស្រែចម្ការដូចគ្នា ។

កុសលៈ បាទ ។

ហមៈ ចឹងបើយើងមិនធ្វើគឺយើងគ្មានអីហូប ហើយយើងប្រយុទ្ធគ្នាដងវៃគ្នាដងលាក់មុខដង ប្តី ទៅមុខប្រពន្ធនៅក្រោយធ្វើស្រែចម្ការ ត្រូវតែធ្វើដើម្បីចិញ្ចឹមជីវិតចឹងបណ្តោយ ។

កុសលៈ ចឹងការសុំទានគេហ្នឹងគឺជារឿងមួយអាក្រក់ឬមួយមិនអាចទទួលយកបាន?

ហមៈ ហើយមិនចេះលួចទៀត ។

កុសលៈ ហើយមិនចេះលួចមិនអី?

ហមៈ គឺសុខចិត្តធ្វើដោយខ្លួនឯងអត់បាត់ទេ ស្រូវក៏ដោយយើងទុកគរចោលនៅស្រែក៏អត់មាន បាត់ដែរ ។

កុសលៈ ទាក់ទងនិងសំនួរហ្នឹងខ្ញុំបានចុះទៅទាក់ទងភូមិផ្សេង ដូចជាអូរគគីរកណ្តាលអូរគគីរក្រោមអី គាត់មានប្រសាសន៍មកថា បញ្ហាអ្នកចាស់គាត់មានសាមគ្គីភាពគ្នាល្អណាស់ ដូចជាមាន លួចមានអីទេ ដូចជាលោកពូនិយាយមិញ ប៉ុន្តែអ្នកចំណូលថ្មី អ្នកមកពីក្នុងមកច្រើនតែ បង្កបញ្ហា តើនៅក្នុងភូមិរបស់ពូហ្នឹងមានបញ្ហាហ្នឹងកើតឡើងទេ?

ហមៈ វាមានខ្លះដែរ ប៉ុន្តែវាមានកំប៉េកកំប៉ុកដូចជាលួចមាន់ លួចទាអីហ្នឹង ។

កុសលៈ ពីមុនមកអត់ដែលមានទេ?

ហមៈ ពីមុនមកអត់មានសោះតែម្តង ម៉ូតូអីក៏ដោយយើងមិនបាច់ទុកក្នុងទេ ទុកតែក្រៅទេ ហើយសម្រាកតាមពីដើមព្រៃដងយើងចេះតែសម្រាកបានអត់មានភ័យខ្លាចអីទេ ព្រោះ យើងទុកចិត្តគ្នា ។

កុសលៈ បាទ ។

ហមៈ ហើយយើងគិតថាម្នាក់ៗយើងខំដើម្បីចិញ្ចឹមជីវិតរៀងខ្លួន យើងអត់មានប៉ះពាល់គ្នាទេ ផ្លូវធម៌គឺចឹងតែម្តង ។

កុសលៈ ចឹងមានសីលធម៌ល្អណាស់?

ហមៈ បាទ!មិនចង់បានអ្វីសម្រាប់រស់តែឯងចង់និយាយចឹង ។

កុសលៈ គិតពីសមូលហភាពទាំងអស់គ្នា ខ្ញុំថាទំលាប់និងល្អខ្ញុំឃើញផ្នែកពីណាមកក៏សសើរថា អ្នកអន្លង់វែងហ្នឹងមិនដែលឃើញអ្នកសុំទាន សំនួរចុងក្រោយទាក់ទងរឿងដីធ្លីទាក់ទងនិងជនបរទេស តើពូគាំទ្រឲ្យរដ្ឋាភិបាលកាត់បន្ថយជនបរទេសដែលទេ ដល់កំរិតណា ជនបរទេសខ្ញុំចង់និយាយថា វៀតណាម ថៃ ចិន ឥឡូវឈ្នួញចិនក៏ចូលមកច្រើនដែលហើយ លោកពូដឹងហើយ លោកពូនៅខាងថ្នាក់ដឹកនាំភូមិឃុំ តើលោកពូគាំទ្រឲ្យរដ្ឋាភិបាលកាត់បន្ថយឥទ្ធិពលជនបរទេសហ្នឹងក្នុងតំបន់នេះដែរទេ?

ហមៈ ខ្ញុំគិតថា សម្រាប់ជនបរទេសដែលចូលមក ជាជំហររបស់ខ្ញុំ ខ្ញុំចង់ឲ្យកាត់បន្ថយណាស់ ព្រោះជាប្រជាពលរដ្ឋយើង ប្រទេសយើងដីវាតូច ។

កុសលៈ បាទ ។

ហមៈ ចឹងបើសិនណាអ្នកគេទិញដី អ្នកមានគេទិញអស់ទៅយើងជាប្រជាពលរដ្ឋគឺលំបាកណាស់ តាមខ្ញុំគិតទេ ជាជំហររបស់ខ្ញុំ ។

កុសលៈ ចឹងកាលមុនលោកថា ធ្វើអីទៅតាមការណែនាំ ពីថ្នាក់លើមក ចឹងបើសិនជាការណែនាំពីរដ្ឋាភិបាលមកថ្នាក់លើមក ពូមិនឯកភាពពូយល់ថាវាខុស តើពូហ៊ានជំទាស់ហ៊ានតវ៉ាដែលឬទេ ពូជាថ្នាក់ដឹកនាំភូមិម្នាក់?

ហមៈ តាមពិតទៅថ្នាក់ដឹកនាំដូចខ្ញុំត្រឹមភូមិហ្នឹង មិនដែលបាននិយាយអីដល់បញ្ហាជនបរទេសអីដែលណា ។

កុសលៈ បាទ ។

ហមៈ យើងមិនបាននិយាយដល់ហ្នឹងទេ គ្រាន់តែជាគំនិត យើងចង់ឲ្យប្រជាពលរដ្ឋយើងរស់នៅលើទឹកដីរបស់យើង ហើយមានទឹកមានដីរបស់យើងសម្រាប់រស់រានមានជីវិតតកូនតចៅទៅទៀត មិនចង់ឲ្យគេមកទិញយកអស់ទេ ចឹងណាស់ ។

កុសលៈ ចឹងសំនួរចុងក្រោយទាក់ទងនិងការផ្សះផ្សារវាល់ថ្ងៃហ្នឹងពូមានដែលសប់អារម្មណ៍ឬនៅមានគិតពីរបបមុនៗមកទេ ពូមានស្ងប់អារម្មណ៍មានម្ចាស់ការលើខ្លួនឯងហើយ តើមាននៅនឹកឃើញពីមុនមកទេ របបពីមុនមក ការលំបាកអីផ្សេងៗនៅមាននឹកឃើញទេ?

ហមៈ សត្តិអារម្មណ៍នៅតែនឹកឃើញដែលហ្នឹង ព្រោះយើងធ្លាប់លំបាកកន្លងមក ពីសេសសង្គ្រាមការលមបាកនៅក្នុងព្រៃផង មិនដែលបានផ្ទះប៉ុននេះនៅទេ ។

កុសលៈ បាទ ។

ហមៈ ទើបចប់សង្គ្រាមទើបយើងបានផ្ទះប៉ុននេះ ក្នុងមួយឆ្នាំធ្វើផ្ទះបួនទៅប្រាំដងធ្វើផ្ទះខ្ទមគ្រាន់តែម៉ាដេក១ ។

កុសលៈ ហើយឆេះអស់ទៅ?

ហមៈ ឆេះអស់ទៅរត់ ។

កុសលៈ ចឹងឥឡូវពូមានលំហ្នឹងមានម្ចាស់ការ មានកន្លែងច្បាស់លាស់?

ហមៈ បាទ!មានលំហ្នឹងហើយ ។

កុសលៈ តាមមើលប្រជាជនរាល់ថ្ងៃក៏មានអារម្មណ៍ចឹងដែលមែនទេ?

ហមៈ បាទ!មានលំហ្នឹង ។

កុសលៈ មានលំហ្នឹងស្ថេរភាពលំហ្នឹង?

ហមៈ បាទ ។

កុសលៈ ចឹងចំពោះព្រឹត្តិការណ៍ក្នុងរបបបីឆ្នាំ ដូចថាពូនៅខាងក្រៅទៅចុះ ឧបមាចឹង ខាងក្នុងឃើញថាមិនមានការយល់គ្នាទៅវិញទៅមក អត់ដឹងថាអ្នកខាងក្រៅហ្នឹងគាត់តស៊ូលំបាកដែរ ចុះលោកពូជាការត្រឹមត្រូវទេ ប្រជាជនកម្ពុជាគួរតែគិត ពេលដែលគិតពីរបបបីឆ្នាំហ្នឹង គួរតែទុកដើម្បីការផ្សះផ្សារជាតិនិងសន្តិភាពគួរតែទុកកំហឹងក្នុងចិត្តពីឯកភាពទេ ពី១ដល់៥ ពូឯកភាពតិចឬក៏ច្រើន គួរយើងទុកកាត់បន្ថយនៃការ លោកពូនិយាយហើយពីមុនថាពារមិនចងពារអីចឹង?

ហមៈ បាទ ។

កុសលៈ ចឹងយើងគួរតែទុកកំហឹងចឹង ចំពោះពូផ្ទាល់នៅមានការថា អ្នកខាងក្នុងមិនយល់ពីអ្នកខាងក្រៅពូមានអារម្មណ៍ចឹងដែលទេ សំនួរទី១ ថា តើយើងគួរទប់កំហឹងក្នុងចិត្ត?

ហមៈ តាមពិតទៅខ្ញុំមិនមានកំហឹងអីទុកក្នុងចិត្តផង ។

កុសលៈ ចង់និយាយថា ប្រជាជនខាងក្នុងជនរងគ្រោះពីរបបបីឆ្នាំ តើគាត់គួរតែទប់កំហឹងនៅក្នុងខ្លួនឬមួយយ៉ាងមេច ដើម្បីការផ្សះផ្សារជាតិ?

ហមៈ អាហ្នឹងខ្ញុំពិបាកដែរ ពីព្រោះថា មនុស្សការយល់មិនដូចគ្នាហើយទី២ទៀត ការរងគ្រោះរបស់គាត់ហើយ ទោះបីខ្ញុំមានការរងគ្រោះដូចគ្នា ការលំបាកដូចគ្នា ចេញចាកពីផ្ទះមកមិនដែលបាននៅស្រុកផង ។

កុសលៈ បាទ!ចឹងសំនួរធំយើងធ្វើយ៉ាងម៉េចទៅ មួយនៅខាងក្រៅមួយនៅខាងក្នុង ឥឡូវយើងផ្សះផ្សារគ្នាហើយយើងមកនៅជាមួយគ្នា?

ហមៈ បាទ ។

កុសលៈ សូម្បីតែនៅក្នុងភូមិក៏មានអ្នកចូលថ្មីមកដែរ ធ្វើម៉េចឲ្យសង្គមមានលក្ខណៈខ្ញុំចង់និយាយថា កុំឲ្យមានពីរទៀត?

ហមៈ បាទ!កុំឲ្យមានពីរ ។

កុសលៈ តើធ្វើយ៉ាងម៉េចទៅចឹង ខ្ញុំសួរដូចជាឆ្ងល់នៅវិញ ធ្វើម៉េចឲ្យយើងជាធ្លុងមួយកុំឲ្យមានពីរតទៀត?

ហមៈ បាទ ។

កុសលៈ កុំឲ្យមានចឹងទៀត កុំឲ្យមានសត្តិអារម្មណ៍បែបហ្នឹងទៀត?

ហមៈ នេះតាមយោបល់ខ្ញុំគួរតែបំភ្លិចចោល បំបាត់ចោលយើងគិតរឿងថ្មីតែម្តងមិនថាខាងក្នុងខាងក្រៅ ។

កុសលៈ ចឹងលោកពូមានដែលប្រាប់រឿងរ៉ាវពីមុនមកដល់កូនស្រីលោកពូដែរ មានដែលនិយាយរឿងពិបាកប្រាប់វាពីមុនមកទេ?

ហមៈ ខ្ញុំធ្លាប់និយាយប្រាប់កូនដែរ កូនកើតមកបានវ័យប៉ុណ្ណឹងហើយយើងមានការលំបាកតិចតួចដែរ ខ្ញុំពរវារត់រហូតតាំងពីឆ្នាំ៨០មក ។

កុសលៈ បាទ ។

ហមៈ ហើយមកដល់ឥឡូវនេះមានការផ្សះផ្សារជាតិហើយ សមាហរណ៍កម្មចប់សង្គ្រាមចាត់ទុកថា ជាសំណាងរបស់កូនដែលបានរស់រានក្នុងសង្គមមួយដ៏ល្អ គិតថាគ្មានអីលើសហ្នឹងទៀតទេ សម្រាប់ជីវិតយើងរស់នៅប្រទេសមានសុខសន្តិភាពហើយមានការរកស៊ីចិញ្ចឹមជីវិតដោយខ្លួនឯងបាន ។

កុសលៈ គាត់បានរៀនដល់ថ្នាក់ណាដែលកូនលោកពូ?

ហមៈ កូនខ្ញុំប្រាប់ចឹងអត់មានអីលើសហ្នឹងទៀតទេ ប្រជាពលរដ្ឋយើងមានការពេញចិត្តក្នុងការរស់នៅជាពិសេសកូនខ្ញុំតែម្តង កើតមកចំប្រទេសស្រួល ។

កុសលៈ ពោរគេ?

ហមៈ ពោរ ។

កុសលៈ រៀនថាក់ទីប៉ុន្មានហើយ?

ហមៈ កូនពូហម និយាយថា រៀនថ្នាក់ទី៤ ។

កុសលៈ ស្អាតផងដូចម៉ាក់ អត់ទៅរៀនទេថ្ងៃនេះ ។

ហមៈ អត់ទេ វ៉ាកងហើយ ។

កុសលៈ ចូលរៀនថ្ងៃណាខែ១០?

ហមៈ ខែ១០ ។

កុសលៈ ក្មួយពូខែ១០បានចូលរៀនដែរ ប្រឹងរៀន?

ហមៈ កូនតែមួយហ្នឹងដឹងបានឲ្យរៀនទៀត គ្មានអីចែកឲ្យវាទេ ក្នុងសង្គមបច្ចុប្បន្ននេះ បើល្ងង់ដូចខ្ញុំពីដើមអីចប់តែម្តង ។

កុសលៈ ចឹងខ្ញុំអស់សំនួរហើយ តើពូមានសំនួរអីចង់ណែនាំទៅក្រុមខ្ញុំដែលចុះមកធ្វើការហ្នឹង ទាក់ទងអ៊ីដែលពូចង់ណែនាំប្រាប់ ខ្ញុំកើតឆ្នាំ៧៤ ខ្ញុំមិនទាន់ដឹងច្រើនដែរ?

ហមៈ បាទ!ខ្ញុំអត់ទេ ប្អូនខ្ញុំចង់និយាយថា ខ្ញុំឈឺក្លេចភ្លាំងច្រើនណាស់ ។

កុសលៈ ចឹង?

ហមៈ បាទ!និយាយខុសនិយាយត្រូវទេ ។

កុសលៈ ដោយសារតែប៉ពាល់ដោយសារតែអីគេមានរបួស?

ហមៈ ចេះដោយសារតែមានរបួសក្បាលផង ឡានបុក ។

កុសលៈ ឡានបុក?

ហមៈ បាទ!ឡានបុកហើយខ្ញុំភ្លេចៗ ។

កុសលៈ បុកនៅពេលណា?

ហមៈ បុកកាលនៅលើភ្នំនោះ ឡានវាថយមកបុកបណ្តោយគាបបែកក្បាល ។

កុសលៈ ដឹកឈើ?

ហមៈ អត់ទេ នៅកន្លែងគេបើកបរហ្នឹង ខ្ញុំឈរជិតគេ ។

កុសលៈ លោកពូមានរូបថតអីចាស់ៗដូចជាជំនាន់៨០-៨១អីមាននៅទេ ។

ហមៈ អត់មានទេ ប្អូនអត់មានផង ។

កុសលៈ ចឹងខ្ញុំសូមអរគុណពូប៉ុណ្ណឹងខ្ញុំមានប៉ុណ្ណឹង ចឹងលោកពូអត់មានអីបន្ថែមទៀតទេ?

ហមៈ ខ្ញុំអត់មានអីទៀតផង ខ្ញុំចង់ឲ្យមានការផ្សះផ្សារជាតិ ។

**ចប់**